# ស្ថានទូតអូស្ត្រាលី ភ្នំពេញ

## <u>សេចក្តីប្រកាសព័ត៌មាន</u>

ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២២

## ការបើកដំណើរការកម្មវិធី
## ភាពជាដៃគូកម្ពុជា-អូស្ត្រាលី សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយភាពធន់

ថ្ងៃនេះ ឯកឧត្តម ព្រឹទ្ធសមាជិក Tim Ayres ឧបការីរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជាឧបការីរដ្ឋមន្ត្រីក្រសួងផលិតកម្ម របស់អូស្ត្រាលី ចូលរួមជាមួយ ឯកឧត្តម វង្សី វិស្សុត រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការប្រចាំការរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅកម្ពុជា បានបើកដំណើរការកម្មវិធីថ្មី ឈ្មោះថា ភាពជាដៃគូកម្ពុជា-អូស្ត្រាលី សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយភាពធន់ Cambodia Australia Partnership for Resilient Economic Development (CAP-RED) ដែលមានថវិកា ៨៧លានដុល្លារអូស្ត្រាលី។

CAP-RED ជាកម្មវិធីថ្មី មានរយៈពេល៥ឆ្នាំ ដែលត្រូវបានបង្កើតឡើង ផ្អែកលើជំនួយជាងមួយទសវត្សរ៍របស់អូស្ត្រាលី ដល់វិស័យកសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធនៅកម្ពុជា តាមរយៈកម្មវិធីខ្សែសង្វាក់តម្លៃកសិកម្មកម្ពុជា-អូស្ត្រាលី (CAVAC) និងកម្មវិធីវិនិយោគលើវិស័យហេដ្ឋារចនាសម្ព័ន្ធ (3i) ដែលទើបតែបានបញ្ចប់ថ្មីៗនេះ។ កម្មវិធីទាំងពីរដែលទើបតែបានបញ្ចប់នេះ បានផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនកម្ពុជានៅតាមជនបទ ជាងពីរលាននាក់។

កម្មវិធី CAP-RED ត្រូវបានបង្កើតឡើង បន្ទាប់ពីមានការពិគ្រោះយោបល់ដ៏ទូលំទូលាយជាមួយទាំងវិស័យសាធារណៈ និងឯកជន អំពីមធ្យោបាយដ៏ល្អប្រសើរបំផុត ដើម្បីជួយសេដ្ឋកិច្ចកម្ពុជាស្តារឡើងវិញបន្ទាប់ពីជំងឺកូវីដ-១៩។ កម្មវិធី CAP-RED នឹងជួយដល់រាជរដ្ឋាភិបាលកម្ពុជា និងសមភាគីពាក់ព័ន្ធផ្សេងៗទៀត បង្កើតគោលនយោបាយនានា ដែលជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយ បរិយាបន្ន ភាពធន់ និងនិរន្តរភាព។

ឯកឧត្តម ព្រឹទ្ធសមាជិក Tim Ayres បានមានប្រសាសន៍ថា "ឆ្នាំនេះជាខួបទី៧០ឆ្នាំ នៃទំនាក់ទំនងការទូតរវាងកម្ពុជា និងអូស្ត្រាលី ហើយកម្មវិធី CAP-RED ជាភស្តុតាងរឹតតែច្បាស់ បន្ថែមទៀតនៃ

ភាពជាដៃគូដ៏យូរអង្វែងរបស់យើងជាមួយប្រទេសកម្ពុជា។ យើងរង់ចាំចែករំលែកចំណេះដឹង និងជំនាញជាមួយសមភាគីកម្ពុជារបស់យើង ដើម្បីបង្កើតបរិយាកាសអំណោយផលសម្រាប់ ការវិនិយោគ ផលិតភាព និងពាណិជ្ជកម្ម»។

ដើម្បីសម្រេចបាននូវលទ្ធផលទាំងនេះ កម្មវិធីនេះនឹងធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រសួងពាក់ព័ន្ធ និងផ្នែកពាក់ព័ន្ធនានាក្នុងវិស័យចំនួនបី ដើម្បីជំរុញកំណើន៖ សេវាហេដ្ឋារចនាសម្ព័ន្ធ កសិកម្មនិងកសិ-កែច្នៃ ព្រមទាំងការអភិវឌ្ឍ ពាណិជ្ជកម្ម ការវិនិយោគ និងសហគ្រាស។ កម្មវិធីនេះនឹងផ្តោតសំខាន់ខ្លាំងលើ ការចែករំលែកការស្រាវជ្រាវ និងចំណេះដឹង ព្រមទាំងផ្តោតលើ សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ផងដែរ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កម្ពុជា បានមានប្រសាសន៍ថា "កម្មវិធី CAP-RED ជាការរួមចំណែកយ៉ាងសំខាន់ ទៅដល់របៀបវារៈនៃការអភិវឌ្ឍសេដ្ឋកិច្ចរបស់កម្ពុជា ដែលគាំទ្រដល់ការស្តារឡើងវិញ ភាពធន់ និងកំណែទម្រង់។ កម្មវិធីនេះនឹងលើកទឹកចិត្តដល់ការវិនិយោគសាធារណៈ និងឯកជន ប្រកបដោយបរិយាបន្ន ដើម្បីជួយជំរុញសេដ្ឋកិច្ចអោយកាន់តែមានភាពចម្រុះ និងបរិយាបន្ន។

តាមរយៈភាពជាដៃគូនេះ យើងរំពឹងថា គ្រួសារកម្ពុជាមួយចំនួន ជាពិសេសគ្រួសារមកពីជនបទក្នុង ប្រទេសកម្ពុជា ជាពិសេស ស្ត្រី កុមារី កុមារ មនុស្សចាស់ ជនមានពិការភាព និងក្រុមងាយរងគ្រោះនឹងមានជីវភាពប្រសើរឡើង ។

**ទំនាក់ទំនងព័ត៌មាន៖** Media.Cambodia@dfat.gov.au